អ អ ក

EAC

**អាជ្ញាធរអគ្គិសនីកម្ពុជា**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ ២៨៥-សណ-១៧ អអក

ភ្នំពេញ, ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ២០១៧

# សេចក្តីជូនដំណឹងរបស់អាជ្ញាធរអគ្គិសនីកម្ពុជា
# ស្តីពីការពិគ្រោះយោបល់លើការកំណត់បញ្ជីថ្លៃលក់អគ្គិសនី តាមយន្តការកែតម្រូវថ្លៃលក់ប្រែប្រួលតាមថ្លៃប្រេងម៉ាស៊ូតឲ្យសេវាករ ឆេង ទូច ធ្វើសេវាកម្មផ្គត់ផ្គង់អគ្គិសនីឲ្យអ្នកប្រើប្រាស់ទូទៅ នៅឃុំជីផាត ស្រុកថ្មបាំង ខេត្តកោះកុង

អាជ្ញាធរអគ្គិសនីកម្ពុជា សូមជម្រាបជូនសាធារណជនដែលជាអ្នកប្រើប្រាស់អគ្គិសនីនៅក្នុងតំបន់ធ្វើសេវាកម្មផ្គត់ផ្គង់អគ្គិសនីរបស់សេវាករ ឆេង ទូច ឲ្យបានជ្រាបថា ដោយសារស្ថានភាពតម្លៃប្រេងម៉ាស៊ូតនៅលើទីផ្សារមានភាពប្រែប្រួលឡើងចុះឥតទៀងទាត់ និងដើម្បីកំណត់បញ្ជីថ្លៃលក់អគ្គិសនីឲ្យសេវាករ ធ្វើសេវាកម្មអគ្គិសនីមានអត្រាថ្លៃលក់ត្រឹមត្រូវ និងយុត្តិធម៌ អាជ្ញាធរអគ្គិសនីកម្ពុជាបានចាត់តាំងមន្ត្រីជំនាញចុះទៅកាន់ទីតាំងធ្វើសេវាកម្មអគ្គិសនីរបស់សេវាករ ដើម្បីពិនិត្យវាស់អត្រាប្រើប្រាស់ប្រេងបរិមាណថាមពលផលិត និងប្រមូលទិន្នន័យពាក់ព័ន្ធនឹងការធ្វើសេវាកម្មអគ្គិសនីដោយបានអញ្ជើញតំណាងអាជ្ញាធរដែនដី និងតំណាងអ្នកប្រើប្រាស់នៅក្នុងតំបន់របស់សេវាករចូលរួមជាអ្នកអង្កេតការណ៍ រួចយកមកធ្វើការសិក្សាថ្លៃដើមអគ្គិសនី និងកំណត់បញ្ជីថ្លៃលក់អគ្គិសនី សម្រាប់ការធ្វើសេវាកម្មអគ្គិសនីនេះ ស្របតាមការកំណត់របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា និងអនុក្រឹត្យលេខ ៥៤.អនក្រ.បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៥ ស្តីពីគោលការណ៍វាយតម្លៃភាពត្រឹមត្រូវនៃចំណាយក្នុងអាជីវកម្មអគ្គិសនី ។ តាមស្ថានភាពតម្លៃប្រេងនៅលើទីផ្សារមានភាពប្រែប្រួលឡើងចុះឥតទៀងទាត់ ដូច្នេះ ដើម្បីធានានិរន្តរភាពនៃការផ្គត់ផ្គង់អគ្គិសនី និងស្ថានភាពហិរញ្ញវត្ថុរបស់សេវាករ និងដើម្បីឲ្យមានយុត្តិធម៌ និងសមធម៌រវាងអ្នកប្រើប្រាស់អគ្គិសនី និងអ្នកធ្វើសេវាកម្មផង អាជ្ញាធរអគ្គិសនីកម្ពុជាបានគណនាថ្លៃដើមអគ្គិសនី និងគ្រោងកំណត់បញ្ជីថ្លៃលក់អគ្គិសនីតាមយន្តការកែតម្រូវថ្លៃលក់ប្រែប្រួលតាមថ្លៃប្រេងម៉ាស៊ូត ដូចក្នុងតារាងខាងក្រោម៖

| | | | | | |
|---|---|---|---|---|---|
| ថ្លៃប្រេងម៉ាស៊ូត(ដុល្លាអាមេរិក/តោន) | 230 | 295 | 360 | 425 | |
| ថ្លៃដើមអគ្គិសនី | 1,572 | 1,672 | 1,772 | 1,872 | |
| ថ្លៃលក់អគ្គិសនី(រៀល/គ.វ.ម៉) | **2,100** | **2,200** | **2,300** | **2,400** | |
| ថ្លៃប្រេងម៉ាស៊ូត(ដុល្លាអាមេរិក/តោន) | 490 | 555 | 620 | 685 | |
| ថ្លៃដើមអគ្គិសនី | 1,972 | 2,072 | 2,172 | 2,272 | |
| ថ្លៃលក់អគ្គិសនី(រៀល/គ.វ.ម៉) | **2,500** | **2,600** | **2,700** | **2,800** | |
| ថ្លៃប្រេងម៉ាស៊ូត(ដុល្លាអាមេរិក/តោន) | 750 | 815 | 880 | 945 | |
| ថ្លៃដើមអគ្គិសនី | 2,372 | 2,472 | 2,572 | 2,672 | |
| ថ្លៃលក់អគ្គិសនី(រៀល/គ.វ.ម៉) | **2,900** | **3,000** | **3,100** | **3,200** | |
| ថ្លៃប្រេងម៉ាស៊ូត(ដុល្លាអាមេរិក/តោន) | 1010 | 1075 | 1140 | 1205 | |
| ថ្លៃដើមអគ្គិសនី | 2,772 | 2,872 | 2,972 | 3,072 | |
| ថ្លៃលក់អគ្គិសនី(រៀល/គ.វ.ម៉) | **3,300** | **3,400** | **3,500** | **3,600** | |

**អាជ្ញាធរអគ្គិសនីកម្ពុជា** : ផ្ទះលេខ ០២ ផ្លូវលេខ ២៨២ (ផ្លូវបត់ស្តាំទី ១ ខាងត្បូងវិមានឯករាជ្យ) សង្កាត់បឹងកេងកង ១ ខណ្ឌចំការមន រាជធានីភ្នំពេញ,
ទូរស័ព្ទ : ០២៣ ២១៧ ៦៥៤ / ៩៨៧ ៨៩៨ ទូរសារ : ០២៣ ២១៤ ១៤៤, អ៊ីម៉ែល : admin@eac.gov.kh ; Website : www.eac.gov.kh

| | | | | | |
|---|---|---|---|---|---|
| ថ្លៃប្រេងម៉ាស៊ូត(ដុល្លាអាមេរិក/តោន) | 1270 | 1335 | 1400 | 1465 | |
| ថ្លៃដើមអគ្គិសនី | 3,172 | 3,272 | 3,372 | 3,472 | |
| ថ្លៃលក់អគ្គិសនី(រៀល/គ.វ៉.ម៉) | **3,700** | **3,800** | **3,900** | **4,000** | |
| ថ្លៃប្រេងម៉ាស៊ូត(ដុល្លាអាមេរិក/តោន) | 1530 | 1595 | 1660 | 1725 | |
| ថ្លៃដើមអគ្គិសនី | 3,572 | 3,672 | 3,772 | 3,872 | |
| ថ្លៃលក់អគ្គិសនី(រៀល/គ.វ៉.ម៉) | **4,100** | **4,200** | **4,300** | **4,400** | |

តាមតារាងខាងលើ នៅពេលថ្លៃប្រេងម៉ាស៊ូតឡើងថ្លៃ ឬចុះថ្លៃតាមចំនួនកំណត់ក្នុងតារាងខាងលើ ពេលនោះ អត្រាថ្លៃលក់អគ្គិសនីរបស់សេវាករអាចឡើង ឬចុះ១០០រៀល/គីឡូវ៉ាត់ម៉ោង តាមចំនួនកំណត់ក្នុងតារាងខាងលើ ។

ដើម្បីឲ្យមានតម្លាភាព អាជ្ញាធរអគ្គិសនីកម្ពុជាស្នើសុំឲ្យ ក្រសួង-ស្ថាប័ន របស់រាជរដ្ឋាភិបាលដែលពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន និងសាធារណជនទាំងអស់មេត្តាពិនិត្យ និងផ្តល់មតិលើឯកសារគណនា វិភាគ វាយតម្លៃកំណត់បញ្ជីថ្លៃលក់អគ្គិសនីឱ្យសេវាករ ជាតារាងថ្លៃលក់តាមថ្លៃប្រេងម៉ាស៊ូតចាប់ពីថ្ងៃជូនដំណឹងនេះ **រហូតដល់ថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៧ ។ ក្រោយថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៧** ឯកសារគណនា វិភាគ វាយតម្លៃបញ្ជីថ្លៃលក់អគ្គិសនីឲ្យសេវាករ នឹងត្រូវចាត់ទុកថាបានឆ្លងកាត់ការពិគ្រោះយោបល់រួច ហើយអាជ្ញាធរអគ្គិសនីកម្ពុជានឹងអាចធ្វើការពិនិត្យ និងអនុម័តលើតារាងបញ្ជីថ្លៃលក់នេះ ទៅតាមការកំណត់របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ។

អាជ្ញាធរអគ្គិសនីកម្ពុជាសូមបញ្ជាក់ថា៖ ការផ្តល់យោបល់មកឲ្យអាជ្ញាធរអគ្គិសនីកម្ពុជាមានមូលដ្ឋានសំអាងគ្រប់គ្រាន់ និងអាចអនុវត្តបានទៅតាមការកំណត់របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា និងអនុក្រឹត្យលេខ៥៤.អនក្រ.បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៥ ហើយសូមឲ្យការផ្តល់យោបល់នេះ រក្សានូវតុល្យភាពឲ្យបានយុត្តិធម៌ រវាងផលប្រយោជន៍របស់អ្នកប្រើប្រាស់ផង និងអ្នកធ្វើសេវាកម្មអគ្គិសនីផង ។

ឯកសារស្នើសុំកំណត់បញ្ជីថ្លៃលក់អគ្គិសនីរបស់សេវាករ ឯកសារគណនា វិភាគ វាយតម្លៃថ្លៃដើមអគ្គិសនី តារាងបញ្ជីថ្លៃលក់អគ្គិសនីតាមថ្លៃប្រេងម៉ាស៊ូតលម្អិត ព្រមទាំងល័ក្ខខ័ណ្ឌសម្រាប់អនុវត្តយន្តការកែសម្រួលបញ្ជីថ្លៃលក់អគ្គិសនីតាមថ្លៃប្រេងម៉ាស៊ូត ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាចក្រកម្ពុជា និងអនុក្រឹត្យលេខ៥៤.អនក្រ.បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៥ មានតម្កល់ទុកនៅ.....សាលាឃុំជីផាត........សម្រាប់សាធារណជនទាំងអស់ដែលមានចំណាប់អារម្មណ៍ពិនិត្យដោយសេរី នៅគ្រប់ពេលម៉ោងធ្វើការ ។

អាស្រ័យហេតុនេះ សូមសាធារណជនទាំងអស់ដែលមានចំណាប់អារម្មណ៍ចង់ពិនិត្យ និងផ្តល់យោបល់មេត្តាជ្រាបជាពត៌មាន ។

**អាជ្ញាធរអគ្គិសនីកម្ពុជា**

**ប្រធាន**

**បណ្ឌិត.ឆី នរិន្ទ**